១១



# សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិនៅស្ងៀម

## និយមន័យ



សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស មានន័យថាជនជាប់ចោទទាំងអស់ត្រូវទទួលបានការសន្មតថាគ្មានទោសរហូតទាល់តែមានភស្តុតាងបញ្ជាក់ថាមានពិរុទ្ធភាពស្របតាមច្បាប់ និងតាមរយៈសេចក្តីសម្រេចស្ថាពរ ហើយសិទ្ធិនេះអនុវត្តនៅគ្រប់ដំណើរការនីតិវិធីតុលាការទាំងអស់ ចាប់ផ្តើមពីដំណាក់កាលឃាត់ខ្លួនដំបូង និងបន្តរហូតដល់ដំណើរការបញ្ចប់នៃការប្តឹងតវ៉ាជាស្ថាពរផងដែរ។ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសចែងថា៖

- ចៅក្រមត្រូវមានភាពមិនលម្អៀង និងមិនត្រូវមានបុរេវិនិច្ឆ័យទៅលើសំណុំរឿងឡើយ។
- អាជ្ញាធរមិនត្រូវអនុញ្ញាតឱ្យប្រព័ន្ធផ្សព្វផ្សាយមានឥទ្ធិពលទៅលើលទ្ធផលនៃសំណុំរឿងសម្រាប់ការវិនិច្ឆ័យទៅពិរុទ្ធភាព ឬភាពគ្មានកំហុសរបស់ជនជាប់ចោទឡើយ។
- មិនគួរសន្មតពិរុទ្ធភាពរបស់ជនជាប់ចោទដោយឈរលើសូចនាករខាងក្រៅឡើយ (ឧ. ឯកសណ្ឋានពន្ធនាគារ)។
- មន្ត្រីសាធារណៈ មិនត្រូវចេញសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទនៅមុនពេលសវនាការបានបញ្ចប់ឡើយ។
- គោលបំណងនៃបណ្តឹងអាជ្ញា គឺដើម្បីពិនិត្យមើលអត្ថិភាពបទល្មើស និងបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនល្មើស។
ប្រសិនបើមានវិមតិសង្ស័យចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទនោះ ជនជាប់ចោទត្រូវសម្រេចថាគ្មានទោស។



សិទ្ធិនៅស្ងៀមផ្សារភ្ជាប់ជាមួយនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។ សិទ្ធិនេះធានាថា បុគ្គលម្នាក់ៗមានសិទ្ធិមិនឆ្លើយទៅនឹងសំណួររបស់មន្ត្រីអនុវត្តច្បាប់ ឬមន្ត្រីតុលាការ។ សិទ្ធិនេះការពារពីការឆ្លើយដាក់បន្ទុកលើខ្លួនឯង។

សិទ្ធិនៅស្ងៀម ត្រូវតែគោរពនៅពេលដំណើរការនីតិវិធីផ្លូវច្បាប់ ហើយជនសង្ស័យត្រូវទទួលបានការប្រាប់អំពីសិទ្ធិនៅស្ងៀមឱ្យបានភ្លាមៗ នៅពេលដែលពួកគេត្រូវបានឃាត់ខ្លួន។

## ក្របខ័ណ្ឌច្បាប់

### ច្បាប់អន្តរជាតិ



សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ត្រូវបានការពារយ៉ាងច្បាស់ដោយមាត្រា ១១ នៃសេចក្តីប្រកាស "ជនគ្រប់រូបដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញស្របតាមច្បាប់នៅក្នុងសនវការជាសាធារណៈ[...]។" សិទ្ធិនេះចែងនៅក្នុងមាត្រា ១៤ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៤០ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

សិទ្ធិនៅស្ងៀមមិនត្រូវបានធានាច្បាស់លាស់នៅក្នុងច្បាប់អន្តរជាតិទេ ប៉ុន្តែត្រូវបានទទួលស្គាល់ថាត្រូវបានបញ្ជាក់ដោយបង្កប់អត្ថន័យនៅក្នុងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមទាំងនៅក្នុងការសន្មតថាគ្មានទោស។

## ច្បាប់ជាតិ

សិទ្ធិសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិនៅស្ងៀម ត្រូវបានការពារដោយមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា "ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ" និងមាត្រា ៥ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។




## សារសំខាន់

សិទ្ធិសន្មតទុកជាមុនថាគ្មានទោស គឺជាធាតុសំខាន់នៃនីតិរដ្ឋ។ សិទ្ធិនេះត្រូវបានធានាថា ពុំមាននរណាម្នាក់ត្រូវបានដាក់ទោសទណ្ឌតាមទំនើងចិត្ត ចំពោះសកម្មភាព ដែលពួកគេមិនបានប្រព្រឹត្តឡើយ។ ជាការកត់សម្គាល់ សិទ្ធិនេះដាក់បន្ទុកភស្តុតាងលើអយ្យការក្នុងការបង្ហាញការចោទប្រកាន់ និងធានាថា ពុំមានបទល្មើសណាមួយត្រូវបានសន្មតទុកនោះទេ រហូតទាល់តែការចោទប្រកាន់នោះត្រូវបានបញ្ជាក់ថាមានពិរុទ្ធភាពហួសពីវិមតិសង្ស័យ។ ប្រសិនបើអយ្យការមិនបានបញ្ជាក់ថា ការចោទប្រកាន់នោះត្រឹមត្រូវទេ ឬប្រសិនបើនៅតែមានវិមតិសង្ស័យ នោះនឹងផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ ដែលត្រូវបានលើកលែងការចោទប្រកាន់។

សិទ្ធិនៅស្ងៀម គឺពិតជាសំខាន់ណាស់ក្នុងការការពារការសន្មតទុកជាមុនថាគ្មានទោស ដោយសារតែសិទ្ធិនេះការពារសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង (ឬសិទ្ធិមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង) សិទ្ធិនេះក៏មានទំនាក់ទំនងជាមួយនឹងសិទ្ធិសន្មតទុកជាមុនថាគ្មានទោសផងដែរ ហើយសិទ្ធិនេះត្រូវបានបង្កើតឡើងដើម្បីការពារជនជាប់ចោទពីការបង្ខំឱ្យផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង និង/ឬឱ្យសារភាពពីពិរុទ្ធភាព។

## ដែនកំណត់

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស គឺមិនមានដែនកំណត់នោះទេ។ ការសន្មតទុកជាមុនថាគ្មានទោស គឺជាបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមានលក្ខណៈដាច់ខាត់ នេះមានន័យថា សិទ្ធិនេះអនុវត្តនៅគ្រប់ពេលវេលា និងគ្រប់កាលៈទេសៈទាំងអស់។ សិទ្ធិនេះមិនមែនជាកម្មវត្ថុនៃលក្ខខណ្ឌរក្សាទុក ដែលលើកឡើងក្នុងសន្ធិសញ្ញា ឬការរឹតត្បិតស្របច្បាប់ នៅពេលមានសង្គ្រាម ឬគ្រាមានអាសន្នសាធារណៈនោះទេ។

ម្យ៉ាងវិញទៀត សិទ្ធិនេះមានការមើលឃើញបែបផ្សេងទៅលើលក្ខណៈដាច់ខាតនៃសិទ្ធិនៅស្ងៀមផងដែរ។ ប្រទេសមួយចំនួនអនុញ្ញាតឱ្យមានការដកហូតនូវសិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទក្នុងអំឡុងពេលសួរសំណួរ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានបង្ហាញនូវក្តីបារម្ភពាក់ព័ន្ធនឹងការដកហូតសិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទ និងបានណែនាំប្រទេសទាំងអស់ ដែលជាភាគីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ធ្វើការពិចារណាឡើងវិញចំពោះការអនុវត្តរបស់ខ្លួន។

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

Sweden Sverige

People Change the World Diakonia

CC BY NC SA